# ព្រឹត្តិបត្រព័ត៌មាន NEC BULLETIN គ.ជ.ប

លេខ ៣ ចេញផ្សាយថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១២


## ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣

( ថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២ )



សកម្មភាពចាក់សន្លឹកឆ្នោតចេញពីហិបឆ្នោត

### មាតិកា


* សភាពការណ៍ទូទៅនៅថ្ងៃបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំង....... ទំព័រទី ២
* គ.ជ.ប បដិសេធបណ្តឹងរបស់គណបក្ស សម រង្ស៊ី សុំរាប់សន្លឹកឆ្នោត....... ទំព័រទី ៤
* លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា....... ទំព័រទី ៥
* រូបថតសកម្មភាពបោះឆ្នោតនៅថ្ងៃបោះឆ្នោត នៅតាមការិយាល័យ............ ទំព័រទី ៨-៩
* គ.ជ.ប បដិសេធបណ្តឹងរបស់គណបក្ស សម រង្ស៊ី ចំនួន ២ ................. ទំព័រទី ១០
* វគ្គបណ្តុះបណ្តាលនៅតាមបណ្តាគណៈកម្មការរាជធានី ខេត្ត........................ ទំព័រទី ១២




សកម្មភាពរាប់សន្លឹកឆ្នោត


necinfo@forum.org.kh www.necelect.org.kh Fax/Phone: (023) 214 374, 214231, Tel: 012 855 018

# សភាពការណ៍ទូទៅនៅថ្ងៃបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ បានប្រព្រឹត្តទៅធម្មតា ហើយលទ្ធផលនៃការបោះឆ្នោតបឋមត្រូវបានប្រកាសនៅរសៀលថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២



*ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប*

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសនៅក្នុងសន្និសីទសារព័ត៌មាន នាល្ងាចថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ១៧:៣០នាទី ថាសភាពការណ៍ទូទៅនៃការបោះឆ្នោត នៅថ្ងៃបោះឆ្នោតបានប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សុវត្ថិភាពល្អ ក្រោមការសង្កេតមើលពីតំណាងគណបក្សនយោបាយសរុបចំនួន ១៣១នាក់ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ អន្តរជាតិសរុបចំនួន ១៤៣២នាក់ និង អ្នកសារព័ត៌មានជាតិ អន្តរជាតិសរុបចំនួន ២០០នាក់។

ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ការបោះឆ្នោតនៅថ្ងៃទី២៩ ខែមករា បានប្រព្រឹត្តទៅធម្មតា ទោះបីមានខេត្តមួយចំនួននៅឯមាត់សមុទ្រមានភ្លៀងធ្លាក់នៅពេលព្រឹកនៅថ្ងៃបោះឆ្នោតក៏ដោយ ក៏ការិយាល័យបោះឆ្នោតបានបើកការបោះឆ្នោតធម្មតា ហើយសភាពការណ៍ទូទៅមិនមានអ្វីគួរឱ្យកត់សម្គាល់ឡើយ។ នៅក្នុងសន្និសីទសារព័ត៌មាននោះឯកឧត្តមប្រធាន គ.ជ.ប បានប្រកាសលទ្ធផល





បឋមនៃការបោះឆ្នោតនៅតាមមណ្ឌលភូមិភាគទាំង៨ ផងដែរ។ ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតមានចំនួន **១១.៤៧០**នាក់ និងអ្នកបានទៅបោះឆ្នោតមានចំនួន



ការតម្រង់ជួរមុខការិយាល័យបោះឆ្នោតនៅខេត្តបន្ទាយមានជ័យ




ការបោះឆ្នោតនៅការិយាល័យលេខ ៣០០១ នៅខេត្តកណ្តាល





សកម្មភាពរាប់សន្លឹកឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោតលេខ ៧០០៦ ខេត្តពោធិ៍សាត់

**១១.៤១២**នាក់។ តាមតួលេខនេះឃើញថា អ្នកអវត្តមានមិនបានទៅបោះឆ្នោតមានចំនួន **៥៨**នាក់។

ជាមួយគ្នានេះ លទ្ធផលបណ្ដោះអាសន្នត្រូវបានប្រកាសកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២ ហើយឃើញថា សន្លឹកឆ្នោតបានការសរុបទាំង៨ភូមិភាគមានចំនួន **១១.៣៨៣**សន្លឹក ក្នុងនោះគណបក្សប្រជាជនកម្ពុជា ទទួលបានចំនួន **៨.៨៨០**សម្លេង រីឯគណបក្សសម រង្ស៊ីទទួលបានចំនួន **២.៥០៣**សម្លេង។

តាមប្រតិទិន ការប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការប្រកាសផ្សាយបញ្ជីបេក្ខជនជាប់ឆ្នោត ត្រូវធ្វើនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២ ក្នុងករណីគ្មានបណ្ដឹង។ ប៉ុន្តែក្នុងករណីមានបណ្ដឹងការប្រកាសលទ្ធផលផ្លូវការធ្វើនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ដែលជាកាលបរិច្ឆេទចុងក្រោយ៕

# ពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី សុំរាប់សន្លឹកឆ្នោតឡើងវិញ នៅខេត្តកំពង់ឆ្នាំង ត្រូវបានបដិសេធ



*កិច្ចប្រជុំ គ.ជ.ប*

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ បានប្រព្រឹត្តទៅនាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១២ ប្រកបដោយសន្តិសុខ សុវត្ថិភាពយ៉ាងល្អប្រសើរ។ អ្នកបោះឆ្នោតចំនួនជាង ៩៩% បានចេញទៅបោះឆ្នោត។ ជាទូទៅការបោះឆ្នោតបានប្រព្រឹត្តទៅរលូនល្អតាមបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក្នុងដំណាក់កាលនៃការបោះឆ្នោតនេះ មានបណ្តឹងមួយត្រូវបានដាក់នៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គធ/ខប) និងបានប្តឹងបន្តមក គ.ជ.ប។

ខេត្តកំពង់ឆ្នាំងស្ថិតនៅក្នុងមណ្ឌលភូមិភាគទី៧ មាន ៨អាសនៈ មានការិយាល័យបោះឆ្នោតចំនួន ១ គឺការិយាល័យលេខ ៧០០៣ ត្រូវបានគណបក្ស សម រង្ស៊ី ប្តឹងបដិសេធមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដោយសុំឱ្យរាប់សន្លឹកឆ្នោតនៅការិយាល័យនោះឡើងវិញ។ ប៉ុន្តែបណ្តឹងរបស់គណបក្ស សម រង្ស៊ី នេះ ត្រូវបានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង(គខប) បដិសេធចោល ដោយយល់ឃើញថា មន្ត្រីការិយាល័យបោះឆ្នោតបានអនុវត្តបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធី ជំពូកទី៧ ប្រការ ៧.៣៤.៩.២ និងប្រការ ៧.៣៤.៩.៣ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។ គណបក្ស សម រង្ស៊ី មិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គខប កំពង់ឆ្នាំង បានបន្តប្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២។ បណ្តឹងនេះត្រូវបាន គ.ជ.ប បដិសេធចោលទៀត ដោយយល់ឃើញថា បន្ទាប់ពីផ្តល់សុពលភាព និងរាប់សន្លឹកឆ្នោតរួចហើយ ច្បាប់បោះឆ្នោតស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ពុំតម្រូវឱ្យគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតផ្តល់សុពលភាពលើសន្លឹកឆ្នោត និងធ្វើការរាប់សន្លឹកឆ្នោតឡើងវិញឡើយ។ ការផ្ទៀងផ្ទាត់ផលបូកនៃចំនួនសន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតលេខ ៧០០៣ ដោយគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតបានអនុវត្តត្រឹមត្រូវ ស្របតាមចំណុច ៧.៣៤.៨ និងចំនុច ៧.៣៤.៩ នៃបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។

តាមលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ បង្ហាញឱ្យឃើញថា សម្រាប់ការិយាល័យលេខ ៧០០៣ ក្នុងខេត្តកំពង់ឆ្នាំង មណ្ឌលភូមិភាគទី៧ គណបក្ស សម រង្ស៊ី ទទួលបានសម្លេងឆ្នោតចំនួន ៨៦សម្លេង ក្នុងចំណោមសន្លឹកឆ្នោតបានការសរុបចំនួន ៤២៣សម្លេង៕

# លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២

នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ នៅតាមមណ្ឌលភូមិភាគទាំង៨។ លទ្ធផលនេះត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ជាតិ និងវិទ្យុជាតិ ហើយព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការចុះផ្សាយនូវលទ្ធផលបណ្ដោះអាសន្ននេះ ដូចខាងក្រោម ៖

**មណ្ឌល ភូមិភាគ ១**

**(រាជធានីភ្នំពេញ)**

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 533 |
| ២ | សម រង្ស៊ី | 285 |
| | **សរុប** | **818** |

**មណ្ឌល ភូមិភាគ ២**

**(ខេត្តកំពង់ចាម)**

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 1,007 |
| ២ | សម រង្ស៊ី | 355 |
| | **សរុប** | **1,362** |

## មណ្ឌល ភូមិភាគ ៣

## (ខេត្តកណ្ដាល)

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 718 |
| ២ | សម រង្ស៊ី | 203 |
| | **សរុប** | **921** |

## មណ្ឌល ភូមិភាគ ៤

## (ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន)

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 1,670 |
| ២ | សម រង្ស៊ី | 479 |
| | **សរុប** | **2,149** |

## មណ្ឌល ភូមិភាគ ៥

## (ខេត្តតាកែវ កំពត និងខេត្តកែប)

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 1,062 |
| ២ | សម រង្ស៊ី | 252 |
| | **សរុប** | **1,314** |

## មណ្ឌល ភូមិភាគ ៦

## (ខេត្តព្រៃវែង និងខេត្តស្វាយរៀង)

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 1,146 |
| ២ | សម រង្ស៊ី | 273 |
| | **សរុប** | **1,419** |

## មណ្ឌល ភូមិភាគ ៧

## (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ)

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 1,396 |
| ២ | សម រង្ស៊ី | 317 |
| | **សរុប** | **1,713** |

## មណ្ឌល ភូមិភាគ ៨

## (ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី)

| ល.រ | ឈ្មោះគណបក្សនយោបាយ (តាមលំដាប់លេខរៀងសន្លឹកឆ្នោត) | សន្លឹកឆ្នោតទទួលបាន |
|---|---|---|
| ១ | ប្រជាជនកម្ពុជា | 1,348 |
| ២ | សម រង្ស៊ី | 339 |
| | **សរុប** | **1,687** |

# រូបថតសកម្មភាពបោះឆ្នោតនៅថ្ងៃបោះឆ្នោត នៅតាម



សកម្មភាពរៀបចំការិយាល័យបោះឆ្នោតលេខ ១០០១ នៅរាជធានីភ្នំពេញ កាលពីថ្ងៃ២៨ ខែមករា



សកម្មភាពពិនិត្យបញ្ជីឈ្មោះបោះឆ្នោតនៅការិយាល័យលេខ ១០០២ រាជធានីភ្នំពេញ



សកម្មភាពតម្រង់ជួរមុខការិយាល័យបោះឆ្នោតលេខ ១០០២ រាជធានីភ្នំពេញ



សកម្មភាពពិនិត្យអត្តសញ្ញាណអ្នកបោះឆ្នោតនៅការិយាល័យលេខ ១០០២ រាជធានីភ្នំពេញ



សកម្មភាពឱ្យសន្លឹកឆ្នោតដល់អ្នកបោះឆ្នោតនៅការិយាល័យលេខ ១០០២ រាជធានីភ្នំពេញ




សកម្មភាពចូលគូសសន្លឹកឆ្នោតនៅក្នុងបន្ទប់សម្ងាត់នៅការិយាល័យលេខ ១០០១ រាជធានីភ្នំពេញ

# ការិយាល័យបោះឆ្នោតនៃមណ្ឌលបោះឆ្នោតមួយចំនួន




សកម្មភាពបោះឆ្នោតនៅការិយាល័យលេខ ៣០០២ ខេត្តកណ្ដាល



ការជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះនៅការិយាល័យលេខ ៣០០២ ខេត្តកណ្ដាល




សកម្មភាពបិទការិយាល័យបោះឆ្នោត និងបិទហិបឆ្នោត នៅការិយាល័យលេខ ១០០២ រាជធានីភ្នំពេញ



ការចាក់សន្លឹកឆ្នោតលើតុរាប់សន្លឹកឆ្នោត នៅការិយាល័យលេខ ១០០២ រាជធានីភ្នំពេញ



សកម្មភាពរៀបចំសន្លឹកឆ្នោតជាពុំនូកនៅការិយាល័យលេខ ៨០០៦ ខេត្តមណ្ឌលគិរី



សកម្មភាពរាប់សន្លឹកឆ្នោតនៅការិយាល័យលេខ ៨០០៦ ខេត្តមណ្ឌលគិរី

# ពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ីចំនួន ២បណ្តឹង ទាក់ទងនឹងការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ត្រូវបានបដិសេធ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញសេចក្តីសម្រេចចំនួន ២ ដាច់ដោយឡែកពីគ្នាដោយបដិសេធបណ្តឹងចំនួន ២ របស់គណបក្ស សម រង្ស៊ី ទាក់ទងនឹងការឃោសនាបោះឆ្នោត បន្ទាប់ពីបានលើកយកបណ្តឹងទាំងនេះមកធ្វើការពិនិត្យ និងពិភាក្សានាសម័យប្រជុំពេញអង្គរបស់ គ.ជ.ប កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២។





ការដង្ហែក្បួនឃោសនារបស់គណបក្សប្រជាជនកម្ពុជានាពេលកន្លងមក

នៅក្នុងសេចក្តីសម្រេចរបស់ គ.ជ.ប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ គ.ជ.ប យល់ឃើញថា ករណីចងបដាឃោសនាកាត់ទទឹងផ្លូវផ្ទុយនឹងចំណុច ៥.១៤.១៣ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គ.ជ.ប មិនអាចលើកយកមកពិចារណាសម្រេចបានឡើយ ដោយ គ.ជ.ប យល់ឃើញថា គណៈកម្មការរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ(គធប) បានទប់ស្កាត់និងធ្វើការដោះស្រាយ ហើយភាគីនោះក៏សុខចិត្តដកយកបដាចេញភ្លាមដោយមិនចចេសរឹងរូស។ គធប ភ្នំពេញ បានអនុវត្តត្រឹមត្រូវនូវតួនាទីរបស់ខ្លួន ដោយបានទប់ស្កាត់ និងដោះស្រាយវិវាទឃោសនាបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣។

សូមបញ្ជាក់ថា បណ្តឹងខាងលើនេះត្រូវបានគណបក្ស សម រង្ស៊ី ដាក់ពាក្យបណ្តឹងទៅ គធប ភ្នំពេញ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ ហើយ គធប ភ្នំពេញ បានធ្វើការដោះស្រាយរួច ដោយខាងភាគីចងបដាយល់ព្រមស្រាយបដាចេញភ្លាមដោយមិនចចេសរឹងរូស។ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ គធប ភ្នំពេញ បានជូនដំណឹងទៅគណបក្ស សម រង្ស៊ី





ការដង្ហែក្បួនឃោសនារបស់គណបក្ស សម រង្ស៊ី នាពេលកន្លងមក

ប៉ុន្តែខាងគណបក្សសម រង្ស៊ី មិនព្រមទទួលយកដំណោះស្រាយនេះ ទើបដាក់ពាក្យប្តឹងមក គ.ជ.ប ហើយត្រូវបាន គ.ជ.ប បដិសេធ។

នៅក្នុងសេចក្តីសម្រេចរបស់ គ.ជ.ប មួយទៀតចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ គ.ជ.ប យល់ឃើញថា ឈ្មោះ ជាម ប៉េអា ទើបតែប្រព្រឹត្តកំហុសជាលើកដំបូងទាក់ទងនឹងការឃោសនាបោះឆ្នោត ហើយសុខចិត្តទទួលយកសេចក្តីសម្រេចរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបាត់ដំបង(គខប) ដែលបញ្ជាក់ឱ្យឃើញថា ឈ្មោះជាម ប៉េអា ទទួលស្គាល់កំហុស និងមានបំណងកែប្រែខ្លួន ដូចនេះ គ.ជ.ប សម្រេចតម្កល់សម្រេចលេខ០៣៦/១២ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ របស់ គខប បាត់ដំបង ទុកជាបានការពេញទាំងមូល និងរឹបអូសវត្ថុតាងប្រាក់ ២០០ដុល្លារអាមេរិក ទុកជាសម្បត្តិរដ្ឋ។

សូមបញ្ជាក់ថា លោក ជាម ប៉េអា ត្រូវបានគណបក្ស សម រង្ស៊ី ប្តឹងចោទថា បានទិញសន្លឹកឆ្នោតពីសមាជិកក្រុមប្រឹក្សាសង្កាត់ម្នាក់របស់ខ្លួនដោយមានទាំងភ័ស្តុតាងនូវទឹកប្រាក់ចំនួន ២០០ដុល្លារអាមេរិក ហើយគណបក្សនេះបានដាក់ពាក្យប្តឹងមក គខប បាត់ដំបងកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១២។ បណ្តឹងនេះត្រូវបានបើកសវនាការកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ដោយ គខប បាត់ដំបងបានសម្រេចពិន័យទៅលើលោក ជាម ប៉េអា ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល ចូលជាថវិការដ្ឋ ប៉ុន្តែគណបក្ស សម រង្ស៊ី មិនទទួលយកសេចក្តីសម្រេចនេះ ទើបដាក់ពាក្យប្តឹងបន្តមក គ.ជ.ប ហើយត្រូវបាន គ.ជ.ប បដិសេធ៕


ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

អ្នកគ្រប់គ្រង លោក ម៉ៃ សារី

ក្រុមនិពន្ធ

លោក ជា សែ

លោក សុខ លាភ

កំរែលំអអក្ខរាវិរុទ្ធ

អ្នកស្រី ទិន សាវត្ថី

អ្នកថតរូប

លោក សាក់ បូរិន

ក្រាហ្វិកកុំព្យូទ័រ

លោក ប៉េង រតនៈ

លោក ចាន់ វិបុល

## វគ្គបណ្តុះបណ្តាលនៅតាមបណ្តាគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គធ/ខប) ស្តីពីការបោះឆ្នោត និងរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣

អនុវត្តតាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ប្រធាន អនុប្រធាន គធ/ខប ដែលជាមន្ត្រីបានទទួលការបណ្តុះបណ្តាលនៅទីស្តីការ គ.ជ.ប កាលពីថ្ងៃទី២៣_២៤ ខែមករា ឆ្នាំ២០១២ បានធ្វើការបណ្តុះបណ្តាលបន្តដល់មន្ត្រីនៅ គធ/ខប មន្ត្រីគណៈកម្មការការិយាល័យបោះឆ្នោត(គកប) តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនៅតាមបណ្តារាជធានី ខេត្ត។

ជាមួយគ្នានេះព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការដកស្រង់ចុះផ្សាយពីសកម្មភាពបើកវគ្គបណ្តុះបណ្តាលនៅតាមបណ្តា គធ/ខប មួយចំនួនដូចខាងក្រោម ៖

***-សកម្មភាពបណ្តុះបណ្តាលនៅ គខប មណ្ឌលគិរី***

គខប មណ្ឌលគិរី បានបើកវគ្គបណ្តុះបណ្តាលដូចគ្នានេះដែរដល់មន្ត្រី គខប មន្ត្រី គកប/គករ តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត តំណាងអាជ្ញាធរខេត្ត និងសន្តិសុខបោះឆ្នោត ដែលមានចំនួនសរុប ២៦នាក់។





*លោក ទី ឈឿន ប្រធាន គខប មណ្ឌលគិរី និងជាគ្រូឧទ្ទេសនាម មានប្រសាសន៍ក្នុងវគ្គបណ្តុះបណ្តាល*

លោក ទី ឈឿន ប្រធាន គខប មណ្ឌលគិរី បានមានប្រសាសន៍ថា វិធីសាស្ត្របណ្តុះបណ្តាលគឺបញ្ជាំងស្លាយ និងពន្យល់ខ្លឹមសារជាក់ស្តែងតាមសៀវភៅណែនាំ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ការចោទជាសំណួរឱ្យសិក្ខាកាមឆ្លើយភ្លាមៗ និងបំផុសឱ្យសិក្ខាកាមសួរចំណុចក្នុងឯកសារមេរៀនណាដែលពុំទាន់យល់ច្បាស់។

លោកបានបន្តថា ឆ្លងតាមការបណ្តុះបណ្តាលរយៈពេល ១ថ្ងៃ ឃើញថា សិក្ខាកាមមានការយល់ដឹងល្អចំនួន ៨៥% យល់ដឹងល្អបង្គួរចំនួន ១០%និងយល់ដឹងបង្គួរចំនួន ៥%។





លោក គិន ផាន អនុប្រធាន គខប មណ្ឌលគិរី និងជាគ្រូឧទ្ទេសនាម





ការអនុវត្តបោះឆ្នោតសាកល្បងក្នុងវគ្គបណ្តុះបណ្តាលនៅ គខប មណ្ឌលគិរី

## -សកម្មភាពបណ្តុះបណ្តាលនៅ គខប ពោធិ៍សាត់





លោក ផាន់ វណ្ណសិទ្ធិ ប្រធាន គខប ពោធិ៍សាត់ និងជាគ្រូឧទ្ទេសនាម ធ្វើការពន្យល់បង្ហាញដល់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល

ជាមួយគ្នានេះដែរ លោក ផាន់ វណ្ណសិទ្ធិ ប្រធាន គខប ពោធិ៍សាត់បានមានប្រសាសន៍ប្រាប់ឱ្យដឹងថា គខប ពោធិ៍សាត់ បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រី គខប មន្ត្រី គកប/គករ តំណាងគណបក្សនយោបាយ តំណាង

អង្គការមិនមែនរដ្ឋាភិបាល តំណាងអាជ្ញាធរខេត្ត និងគណៈកម្មការសន្តិសុខឱ្យបានយល់ដឹងអំពីនីតិវិធី បច្ចេកទេស និងចំណុចសំខាន់ៗនៃកិច្ចប្រតិបត្តិការបោះឆ្នោត រាប់សន្លឹកឆ្នោត ព្រមទាំងឱ្យបានយល់អំពីបទបញ្ញត្តិនានា និងចេះរួមសហការ អនុវត្តតាមតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ យុត្តិធម៌ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។





*ការអនុវត្តបោះឆ្នោតសាកល្បងក្នុងវគ្គបណ្តុះបណ្តាលនៅ គខប ពោធិ៍សាត់*

លោកបានឱ្យដឹងទៀតឃើញថា តាមរយៈការបណ្តុះបណ្តាលរយៈពេល ១ថ្ងៃ សិក្ខាកាមដែលចូលរួមទាំងអស់ចំនួន ២៥នាក់ មានការយល់ដឹងអំពីនីតិវិធីគោលការណ៍បច្ចេកទេស សម្រាប់ការបោះឆ្នោត រាប់សន្លឹកឆ្នោត និងការវេចខ្ចប់សម្ភារឯកសារនានាពាក់ព័ន្ធនឹងការបោះឆ្នោតបានយ៉ាងល្អប្រសើរ។

**-សកម្មភាពបណ្តុះបណ្តាលនៅ គខប ព្រៃវែង**





*សកម្មភាពគ្រូឧទ្ទេសនាមនៅ គខប ព្រៃវែង ធ្វើការណែនាំអំពីនីតិវិធីដល់សិក្ខាកាម*

ដោយមានការយកចិត្តទុកដាក់ក្នុងការរៀបចំការបោះឆ្នោត និងទទួលបានការណែនាំពី គ.ជ.ប ផងនោះ គខប ព្រៃវែង ក៏បានបើកវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការវេចខ្ចប់សម្ភារឯកសារ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ដល់មន្ត្រី គខប មន្ត្រី គកប/គកស តំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត សរុបចំនួន ៣០នាក់ នៅទីស្នាក់ការ គខប ព្រៃវែងផងដែរ។

លោក ហួត ផាន ប្រធាន គខប ព្រៃវែង និងជាគ្រូឧទ្ទេសនាម បានមានប្រសាសន៍ឱ្យដឹងថា ឯកសារដែលបានយកមកបណ្តុះបណ្តាលរួមមានសៀវភៅណែនាំស្តីពីតួនាទី និងភារកិច្ចរបស់មន្ត្រី គកប/គករ នីតិវិធីនៃដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត នីតិវិធីនៃការដាក់ និងទទួលពាក្យបណ្តឹង និងបច្ចេកទេសនៃការវេចខ្ចប់សម្ភារឯកសារបោះឆ្នោតនៅពេលបញ្ចប់ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ លោកបានបញ្ជាក់បន្ថែមថា ក្រោយពីបានធ្វើបទបង្ហាញ ព្រមទាំងមានការពន្យល់បកស្រាយយ៉ាងក្បោះក្បាយនូវខ្លឹមសារមេរៀនដោយលើកឧទាហរណ៍ និងបើកឱ្យមានការចោទជាសំណួររួចមក ឃើញថា សិក្ខាកាមទាំងអស់មានការយល់ដឹងបានល្អប្រសើរ។

**-សកម្មភាពបណ្តុះបណ្តាលនៅ គខប សៀមរាប**




*លោក នឹម វ៉ាន់សំ ប្រធាន គខប សៀមរាប ធ្វើការពន្យល់ដល់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល*

គខប សៀមរាប បានបើកវគ្គបណ្តុះបណ្តាលស្តីពីការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ នៅទីស្នាក់ការ គខប។ សិក្ខាកាមចូលរួមមានមន្ត្រី គខប តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងស្នងការនគរបាលខេត្ត សរុបចំនួន ៣១នាក់។

**-សកម្មភាពបណ្តុះបណ្តាលនៅ គខប ព្រះសីហនុ**




*វគ្គបណ្តុះបណ្តាលនៅ គខប ព្រះសីហនុ*

គខប ព្រះសីហនុ ក៏បានឱ្យដឹងផងដែរថា គខប បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីគខប តំណាងគណបក្សនយោបាយ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៨នាក់៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៣ ឆ្នាំ២០១២

| ល.រ | មណ្ឌលភូមិភាគ | ចំនួន រាជធានី ខេត្ត | ចំនួន ការិយាល័យ | គណបក្ស ប្រជាជនកម្ពុជា | គណបក្ស សម រង្ស៊ី | សន្លឹកឆ្នោត បានការ | សន្លឹកឆ្នោត មិនបានការ | សន្លឹកឆ្នោត ក្នុងហិប |
|---|---|---|---|---|---|---|---|---|
| 1 | មណ្ឌលភូមិភាគ ១ | 1 | 2 | 533 | 285 | 818 | 2 | 820 |
| 2 | មណ្ឌលភូមិភាគ ២ | 1 | 3 | 1,007 | 355 | 1,362 | 5 | 1,367 |
| 3 | មណ្ឌលភូមិភាគ ៣ | 1 | 2 | 718 | 203 | 921 | 1 | 922 |
| 4 | មណ្ឌលភូមិភាគ ៤ | 5 | 7 | 1,670 | 479 | 2,149 | 1 | 2,150 |
| 5 | មណ្ឌលភូមិភាគ ៥ | 3 | 4 | 1,062 | 252 | 1,314 | 1 | 1,315 |
| 6 | មណ្ឌលភូមិភាគ ៦ | 2 | 3 | 1,146 | 273 | 1,419 | 5 | 1,424 |
| 7 | មណ្ឌលភូមិភាគ ៧ | 5 | 6 | 1,396 | 317 | 1,713 | 1 | 1,714 |
| 8 | មណ្ឌលភូមិភាគ ៨ | 6 | 6 | 1,348 | 339 | 1,687 | 11 | 1,698 |
| | សរុបរួម | 24 | 33 | 8,880 | 2,503 | 11,383 | 27 | 11,410 |

រាជធានីភ្នំពេញថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១២